# ព្យាបាលអ្នកឈឺ

*អែលឌើរ ដាល្លិន អេច អូក*
*នៃកូរ៉ុមពួកសាវកដប់ពីរនាក់*

នៅក្នុងគ្រានេះពិភពលោកទាំងមូលកាន់តែជួបនឹងភាពចលាចល ហើយមនុស្សដែលមានជំនឿកាន់តែច្រើន កំពុងតែ ងាកទៅរកព្រះអម្ចាស់ សម្រាប់ពរជ័យនៃការលួងលោម និងការព្យាបាល។ ខ្ញុំមានបំណងប្រាថ្នានិយាយ ទៅកាន់ អ្នកស្ដាប់ទាំងឡាយ អំពីការព្យាបាលអ្នកឈឺដោយអ្នកកាន់បព្វជិតភាព---តាមរយៈវិទ្យាសាស្ត្រផ្នែកពេទ្យ ការអធិស្ឋានដោយសេចក្ដីជំនឿ និងតាមរយៈពរជ័យនៃបព្វជិតភាព។

ពួកបរិសុទ្ធថ្ងៃចុងក្រោយជឿ និងអនុវត្តចំណេះវិជ្ជាផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវេជ្ជាដ៏ប្រសើរបំផុតដែលមាន។ យើង បរិភោគអាហារដែលមានជីវជាតិ ហាត់ប្រាណ និងការអនុវត្តន៍ផ្សេងទៀតដើម្បីរក្សាសុខភាព និងចូលរួមហ្វឹកហាត់ ជំនួយផ្នែកសុខភាពពីអ្នកជំនាញទៀតផង ដូចជាពីគ្រូពេទ្យ និងពីគ្រូពេទ្យវះកាត់ដើម្បីស្ដារសុខភាពឡើងវិញ។

ការប្រើប្រាស់វិទ្យាសាស្ត្រផ្នែកពេទ្យ គឺមិនមែនប្រឆាំងជាមួយនឹងការអធិស្ឋានដោយក្តីជំនឿ និងការទុកចិត្តទៅលើពរជ័យបព្វជិតភាពរបស់យើងនោះទេ។ នៅពេលមនុស្សម្នាក់ស្នើសុំការប្រសិទ្ធពរបព្វជិតភាព នោះលោកព្រិកហាំ យ៉ង់ បានសួរថា៖ «តើអ្នកមានប្រើឱសថអ្វីហើយឬនៅ?» ចំពោះអស់អ្នកដែលនិយាយថា ទេ ពីព្រោះ "យើងមានបំណងចង់ឱ្យ អែលឌើរដាក់ដៃលើក្បាលយើង ហើយយើងមានជំនឿថាយើងអាចជា" នោះប្រធាន យ៉ង់ បានឆ្លើយថា៖

«នោះវាមិនដូច្នេះទេចំពោះសេចក្តីជំនឿរបស់ខ្ញុំ។ ប្រសិនបើយើងឈឺ ហើយសុំឱ្យព្រះអម្ចាស់ប្រទានពរដល់យើង នោះ យើងត្រូវតែធ្វើនូវអ្វីដែលចាំបាច់ចំពោះយើងដែលត្រូវធ្វើ យោងទៅលើការយល់ដឹងរបស់ខ្ញុំចំពោះដំណឹងល្អនៃសេចក្ដីសង្គ្រោះ ខ្ញុំក៏សុំឱ្យព្រះអម្ចាស់ធ្វើឱ្យស្រូវសាឡី និងពោតរបស់ខ្ញុំដុះដែរ បើគ្មានការភ្ជួររាស់  និងការដាក់គ្រាប់ពូជនៅក្នុង ដីទេ នោះវានឹងមិនអាចទៅរួចទេ តាមការយល់ដឹងរបស់ខ្ញុំវាអនុវត្តដូចគ្នាចំពោះថ្នាំកែរោគ ហើយ [បន្ទាប់មក] ត្រូវទូល សូមព្រះវរបិតាដែលគង់នៅស្ថានសួគ៌...បួងសួងស្នើសុំឱ្យព្យាបាលរូបកាយរបស់ខ្ញុំ»។ 1

ជាការពិតណាស់យើងមិនរង់ចាំរហូតដល់វិធីសាស្ត្រផ្សេងៗប្រើការលែងកើតពីមុនពេលយើងអធិស្ឋានដោយសេចក្ដីជំនឿឬពរជ័យនៃបព្វជិតភាពសំរាប់ការព្យាបាលនោះទេ។ នៅក្នុងគ្រាបន្ទាន់ ការអធិស្ឋាន និងការប្រសិទ្ធពរត្រូវធ្វើឡើងមុនគេ។ ជាញឹកញាប់យើងស្វែងរកវាល់គ្រប់មធ្យោបាយ។ ស្របជាមួយគ្នានោះ ព្រះគម្ពីរបានបង្រៀនយើងថាយើងគួរតែ «ចូរអធិស្ឋានជានិច្ច» (គ. និង ស. 90:24) ហើយគ្រប់ការណ៍ទាំងនេះត្រូវបានប្រព្រឹត្តឡើងក្នុងប្រាជ្ញា និងរបៀបរៀបរយ (សូមមើល ម៉ូសាយ 4:27)។

យើងដឹងថាការអធិស្ឋានដោយសេចក្តីជំនឿ ដោយការបន្លឺសម្លេងតែម៉្យាងនៅក្នុងផ្ទះរបស់យើង ឬនៅកន្លែងថ្វាយបង្គំនានាក្តី គឺមានផលក្នុងការព្យាបាលអ្នកឈឺ។ ព្រះគម្ពីរជាច្រើនបានសំដៅទៅលើអំណាចនៃសេចក្តីជំនឿនៅក្នុងការព្យាបាលបុគ្គលម្នាក់ៗ។ សាវកយ៉ាកុបបានបង្រៀនយើងថាយើងគួរ «អធិស្ឋានឱ្យគ្នាទៅវិញទៅមកដើម្បីឱ្យ បានជាចុះ» បន្ថែមពីលើនេះទៀត «ត្បិតសេចក្តីទូលអង្វរដ៏អស់ពីចិត្តរបស់មនុស្សសុចរិត នោះពូកែណាស់» (យ៉ាកុប 5:16 )។ នៅពេលស្ត្រីម្នាក់បានប៉ះព្រះយេស៊ូវ ហើយបានជានោះទ្រង់បានប្រាប់នាងថា៖ «សេចក្តីជំនឿរបស់នាង បានជួយនាងហើយ» (ម៉ាថាយ 9:22 សូមមើលផងដែរ ម៉ាកុស 10:46--52 លូកា 18:35--43 )។ ស្រដៀងគ្នានេះ ដែរព្រះគម្ពីរមរមនបានបង្រៀនយើងថា ព្រះអម្ចាស់ «ធ្វើការដោយព្រះចេស្តា ស្របតាមសេចក្តីជំនឿនៃកូនចៅ មនុស្ស...»។ (មរ៉ូណៃ 10:7 )។

ថ្មីៗនេះការស្រាវជ្រាវទូទាំងប្រទេសបានបង្ហាញថាជនជាតិអាមេរិកកាំងជិត 8 នាក់ក្នុងចំណោម 10 នាក់ «ជឿថា អព្ភូតហេតុនៅតែកើតមាននាសព្វថ្ងៃនេះ ដូចនៅជំនាន់បុរាណដែរ» ការស្រាវជ្រាវបានបង្ហាញថាពួកគេបាន «ទទួលបទពិសោធន៍ ឬបានធ្វើជាសាក្សីចំពោះការព្យាបាលដ៏ទេវភាព» 2 ពួកបរិសុទ្ធថ្ងៃចុងក្រោយជាច្រើនមាន បទពិសោធន៍ ចំពោះព្រះចេស្តានៃសេចក្តីជំនឿក្នុងការព្យាបាលអ្នកឈឺ។ យើងក៏បានឮឧទាហរណ៍ច្រើន ក្នុងចំណោមប្រជាជន នៃសេចក្តីជំនឿនៅក្នុងព្រះវិហារផ្សេងទៀត។ អ្នកកាសែតតិចសាសម្នាក់បានពិពណ៌នាអំពីអព្ភូតហេតុដូច្នេះ។ ខណៈពេលក្មេងស្រីអាយុប្រាំឆ្នាំស្រាប់តែភ្លាមៗ មានបញ្ហាក្នុងការដកដង្ហើម និងគ្រុនក្តៅ នោះឪពុកម្តាយរបស់នាង ប្រញាប់ប្រញាល់នាំនាងទៅមន្ទីរពេទ្យ។ ទំរាំដល់នាងទៅដល់ តម្រងនោម និងបេះដូងរបស់នាងផ្អាកដំណើរការ ជម្ងឺគ្រុនរបស់នាងឡើងកំដៅដល់ 41.7 អង្សាសេ ហើយខ្លួនរបស់នាងឡើងក្រហម ព្រមជាមួយនឹងពណ៌ស្វាយជាំ។ វេជ្ជបណ្ឌិតបាននិយាយថា សេរីរាង្គរបស់នាងងាប់ដោយសារជាតិពុលដោយគ្មានមូលហេតុ។ នៅពេលដំណឹងនេះលេចឮដល់គ្រួសារ និងមិត្តភក្តិ ដោយសេចក្តីភ័យខ្លាចដល់ព្រះ មនុស្សចាប់ផ្តើមអធិស្ឋានឱ្យនាង ហើយការអធិស្ឋានពិសេស បានប្រារព្ធឡើងនៅ សាលាប្រជុំប្រូតេស្តង់ នៅក្នុងទីក្រុងវ៉ាកូ រដ្ឋតិចសាស។ វាអស្ចារ្យ ណាស់ រំពេចនោះនាងបាន វិលត្រឡប់មកពីការជិតស្លាប់ ហើយបានត្រឡប់មកពីមន្ទីរពេទ្យវិញ ជាងមួយសប្តាហ៍បន្តិចប៉ុណ្ណោះ។ ជីតារបស់នាងបានសរសេរថា៖ «ជីវិតរបស់នាងបានបង្ហាញថា ព្រះពិតជាឆ្លើយតបចំពោះការអធិស្ឋាន ហើយអព្ភូតហេតុពិត ជាកើតមាន»។ 3

ពិតណាស់ដូចជាអ្វីដែលព្រះគម្ពីរមរមនបានបង្រៀនថា ព្រះ«នឹងសម្តែងរូបអង្គទ្រង់ ដល់អ្នកណាដែលជឿដល់ទ្រង់ ដោយព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ មែនហើយ គឺគ្រប់ទាំងសាសន៍ គ្រប់ពូជមនុស្ស គ្រប់ភាសា និងគ្រប់ទាំងប្រជាជន ដោយសម្តែងអព្ភូតហេតុទាំងឡាយ...នៅក្នុងចំណោមកូនចៅមនុស្ស ស្របតាមសេចក្តីជំនឿរបស់ពួកគេ» (នីហ្វៃទី 2  26:13 )។

សំរាប់អ្នកស្តាប់ដែលនៅទីនេះ--- ទាំងមនុស្សពេញវ័យ និងយុវជនដែលកាន់អំណាចបព្វជិតភាពមិនយូរ

ប៉ុន្មាន អ្នកនឹងទទួលអំណាចនេះ--- ខ្ញុំនឹងផ្តោតការនិយាយរបស់ខ្ញុំ ទៅលើពរជ័យនៃការព្យាបាល រួមទាំងព្រះចេស្តា នៃបព្វជិតភាព។ យើងមានអំណាចបព្វជិតភាពនេះ ហើយយើងគួរតែរៀបចំខ្លួនប្រើប្រាស់ឱ្យបានសមរម្យ។ ថ្មីៗនេះគ្រោះធម្មជាតិ និងបញ្ហាហិរញ្ញវត្ថុបានកើនឡើង ដែលបង្ហាញដល់យើងថាយើងនឹងត្រូវការអំណាចនេះ កាន់តែច្រើនឡើងនៅពេល អនាគត ជាងកាលពីអតីកិលា។

ព្រះគម្ពីរជាច្រើនបានបង្រៀនថា អ្នកបំរើរបស់ព្រះអម្ចាស់ «នឹងដាក់ដៃលើមនុស្សជំងឺឱ្យបានជាផង» (ម៉ាកុស  16:18 សូមមើលផងដែរ ម៉ាថាយ 9:18 ម៉ាកុស 5:23, 6:5, 7:32--35, 16:18 លូកា 4:40 កិច្ចការពួកសាវក 9:12, 17, 28:8 គ. និង ស.  42:44, 48, 66:9 )។ អព្ភូតហេតុកើតមាននៅពេលអំណាចបព្វជិតភាព ត្រូវបានប្រើប្រាស់ដើម្បី ប្រទានពរដល់អ្នកឈឺ។ ខ្ញុំធ្លាប់មានអព្ភូតហេតុទាំងនេះ។ កាលនៅជាក្មេងប្រុស និងក៏ដូចជាបុរសម្នាក់ខ្ញុំបានឃើញ អព្ភូតហេតុនៃការព្យាបាល គឺដូចគ្នានឹងអ្វីដែលបានកត់ត្រានៅក្នុងព្រះគម្ពីរ និងដូចអ្នករាល់គ្នាជាច្រើនផងដែរ។

មានប្រាំចំណុចដើម្បីប្រើប្រាស់សិទ្ធិអំណាចបព្វជិតភាពដើម្បីប្រសិទ្ធពរដល់អ្នកឈឺៈ  (1) ការចាក់ប្រេង (2) ពិធីផ្សាភ្ជាប់នូវការចាក់ប្រេង (3) សេចក្តីជំនឿ (4) ពាក្យអធិស្ឋាន និង (5) តាមព្រះហឫទ័យរបស់ព្រះអម្ចាស់។

## ការចាក់ប្រេង

ជាញឹកញាប់ព្រះគម្ពីរសញ្ញាចាស់បាននិយាយពីពិធីចាក់ប្រេងជាមួយនឹងប្រេង ដែលជាផ្នែកមួយនៃពរជ័យដែលបាន ប្រគល់ឱ្យដោយអំណាចបព្វជិតភាព (ឧទាហរណ៍ និក្ខមនំ  28:41 សាំយូអែលទី 1  10:1, 16:13 សាំយូអែលទី 2  5:3 )។ ការចាក់ប្រេងតាំង គឺត្រូវបានប្រកាសថា សម្រាប់ញែកចេញជាបរិសុទ្ធ (សូមមើល លេវីវិន័យ 8:10--12 ) ហើយប្រហែលជាអាចមើលឃើញនិមិត្តរូប នៃពរជ័យដែលបានចាក់ស្រោចពីព្រះវរបិតាសួគ៌ ដែលជាផលនៃសកម្មភាពដ៏ពិសិដ្ឋនេះផងដែរ។

នៅក្នុងព្រះគម្ពីរសញ្ញាថ្មី យើងបានអានថា សាវករបស់ព្រះយេស៊ូវ «លាបប្រេងឱ្យមនុស្សជំងឺជាច្រើនបានជាដែរ» (ម៉ាកុស 6:13 )។ នៅក្នុងគម្ពីរ យ៉ាកុប បង្រៀនអំពីតួនាទីនៃការលាបប្រេងនៅក្នុងការផ្សាភ្ជាប់ជាមួយធាតុផ្សេងៗ ក្នុងការព្យាបាលអ្នកឈឺ ដោយអំណាចបព្វជិតភាពៈ

«តើពួកអ្នករាល់គ្នាណាឈឺឬទេ? ត្រូវឱ្យអ្នកនោះហៅពួកចាស់ទុំក្នុងពួកជំនុំ មកអធិស្ឋានឱ្យចុះ ព្រមទាំងលាបប្រេងឱ្យ ដោយនូវព្រះនាមព្រះអម្ចាស់ផង នោះពាក្យអធិស្ឋាននៃសេចក្តីជំនឿនឹងជួយសង្គ្រោះដល់មនុស្សឈឺនោះ ហើយព្រះអម្ចាស់ទ្រង់នឹងប្រោសឱ្យ គាត់បានជា» (យ៉ាកុប 5:14--15 )។

## ពិធីផ្សាភ្ជាប់នូវការចាក់ប្រេង

នៅពេលនរណាម្នាក់បានតែងតាំងដោយអំណាចបព្វជិតភាពមិលគីស្សាដែក នោះការចាក់ប្រេងតាំងត្រូវបានផ្សាភ្ជាប់ដោយសិទ្ធិអំណាចដូចគ្នា។ ដើម្បីផ្សាភ្ជាប់អ្វីមួយមានន័យថាជាការអះអាង ជាការចងភ្ជាប់សំរាប់គោលបំណងនាពេល អនាគត។ នៅពេលអែលឌើរលាបប្រេងឱ្យអ្នកឈឺ និងផ្សាភ្ជាប់នូវការចាក់ប្រេង នោះបានបើកទ្វារស្ថានសួគ៌ ដើម្បី ព្រះអម្ចាស់ចាក់ព្រះពរ តាមព្រះហឫទ័យរបស់ទ្រង់សំរាប់មនុស្សឈឺចាប់នោះ។ ប្រធានព្រិកហាំ យ៉ង់ បានបង្រៀនថា៖

«ពេលខ្ញុំដាក់ដៃលើអ្នកឈឺ ខ្ញុំរំពឹងចង់បានអំណាចនៃការព្យាបាល និងអានុភាពរបស់ព្រះប្រគល់ឱ្យខ្ញុំដើម្បីផ្តល់ទៅ អ្នកជម្ងឺ និងបណ្តេញជំងឺចេញ។ នៅពេលយើងបានរៀបចំ ពេលយើងបានកាន់គ្រឿងប្រដាប់បរិសុទ្ធចំពោះព្រះភក្ត្រ៍ព្រះអម្ចាស់ នោះអំណាចនឹងហូរចុះមកពីព្រះដ៏មហិមាអាចផ្តល់ឱ្យតាមរយៈរោងឧបោសថ ដល់អ្នកប្រសិទ្ធពរ ចូរទៅក្នុងប្រពន្ធ័រាងកាយអ្នកជម្ងឺ ហើយធ្វើឱ្យអ្នកឈឺនោះជាសះស្បើយឡើងវិញ...»។ 4

ទោះជាយើងដឹងថាករណីដូច្នេះជាច្រើនថា មនុស្សជាច្រើន ដែលត្រូវបានប្រសិទ្ធពរ ដោយសិទ្ធិអំណាចបព្វជិតភាព ត្រូវបានជាសះស្បើយក្តី ក៏យើងកម្រនឹងលើកយករឿងនេះមកប្រជុំជាសាធារណៈណាស់ ពីព្រោះវិវរណៈសម័យ ទំនើបបានដាស់តឿនយើងថាមិនត្រូវ៖ «អួត [ខ្លួនរបស់យើង] ពីការណ៍ទាំងនេះ នៅចំពោះ ពិភពលោក ត្បិតការណ៍ ទាំងនេះត្រូវបានប្រទានដល់អ្នក សំរាប់ផលប្រយោជន៍ដល់អ្នក និងសំរាប់សេចក្តីសង្គ្រោះ» (គ. និង ស. 84:73 )។

## សេចក្តីជំនឿ

សេចក្តីជំនឿមានសារៈសំខាន់ណាស់ចំពោះការព្យាបាល ដោយអំណាចនៃស្ថានសួគ៌។ ព្រះគម្ពីរមរមនបានបង្រៀនយើងថា «ព្រោះបើសិនជាគ្មានសេចក្តីជំនឿ នៅក្នុងចំណោមកូនចៅមនុស្សទេ នោះព្រះទ្រង់ពុំអាចសម្តែងអព្ភូតហេតុ នៅក្នុងចំណោមពួកគេបានឡើយ» (អេធើរ 12:12 សូមមើលផងដែរ គ. និង ស. 35:9 នីហ្វៃទី 1 7:12 )។ នៅក្នុងសុន្ទរកថា គួរឱ្យចាប់អារម្មណ៍មួយស្តីអំពីការព្យាបាលអ្នកឈឺ ប្រធានស្ពេនស៊ើរ ដបុលយូ ឃឹមបឹល បានមានប្រសាសន៍ថា៖

«ជាញឹកញាប់ការត្រូវការសេចក្តីជំនឿគឺមិនអាចកំណត់បានឡើយ។ ជាញឹកញាប់អ្នកឈឺ និងក្រុមគ្រួសារហាក់បីដូចជា ពឹងផ្អែកទាំងស្រុងទៅលើអំណាចនៃបព្វជិតភាព និងអំណោយទាននៃការព្យាបាល ដែលពួកគេសង្ឃឹមថា បងប្អូនប្រុស ដែលធ្វើការព្យាបាលទាំងនោះអាចមាន ដែលជាការទទួលខុសត្រូវដ៏ធំអាស្រ័យលើអ្នកប្រសិទ្ធិពរនោះ...។ ធាតុដ៏សំខាន់ បំផុតគឺសេចក្តីជំនឿរបស់បុគ្គលម្នាក់ៗ នៅពេលមនុស្សម្នាក់មានស្មារតី និងដឹងខុសត្រូវ។ «សេចក្តីជំនឿរបស់នាង បានជួយសង្គ្រោះនាងហើយ» (ម៉ាថាយ 9:22 ) ដែលបាននិយាយឡើងវិញជាញឹកញាប់ដោយលោកចៅហ្វាយ ដូចជាពាក្យបន្ទរនៅក្នុងបទចំរៀង»។ 5

ប្រធាន យឹមប៊ឹល ធ្លាប់បានផ្តល់យោបល់ថា៖ «ជារឿយៗការព្យាបាលប្រហែលជាចង្អុលបង្ហាញអំពី ការខ្វះសេចក្តីជំនឿ ឬអ្នកឈឺម្នាក់ព្យាយាមឆ្លងកាត់ការទទួលខុសត្រូវក្នុងការអភិវឌ្ឍន៍សេចក្តីជំនឿរបស់ពួកអែលឌើរជាជាងខ្លួនឯង»។ គាត់បាននិយាយពីស៊ិស្ទើរស្មោះត្រង់ម្នាក់ដែលបានទទួលពរជ័យបព្វជិតភាព។ ពេលគាត់ត្រូវបានគេសួរនៅថ្ងៃបន្ទាប់ ប្រសិនបើគាត់មានបំណងចង់បានការប្រសិទ្ធពរម្តងទៀត នាងបានឆ្លើយថា៖ «ទេ ខ្ញុំបានលាបប្រេង និងបានប្រសិទ្ធពរ រួចហើយ។ ពិធីការទាំងឡាយបានធ្វើរួចហើយ។ ឥឡូវនេះវាអាស្រ័យលើខ្ញុំក្នុងការទាមទារយកពរជ័យរបស់ខ្ញុំ តាមរយៈសេចក្តីជំនឿរបស់ខ្ញុំ»។ 6

## ពាក្យអធិស្ឋាន

ផ្នែកមួយទៀតចំពោះពរជ័យបព្វជិតភាពគឺពាក្យអធិស្ឋាន ដែលបាននិយាយដោយអែលឌើរ បន្ទាប់ពីគាត់បានផ្សាភ្ជាប់នូវការចាក់ប្រេងតាំងរួចហើយ។ ពាក្យពេចន៍ទាំងនេះអាចមានសារៈសំខាន់ខ្លាំងណាស់ ប៉ុន្តែអត្ថន័យរបស់វាមិនសំខាន់ទេ ហើយវាក៏មិនបានកត់ត្រាទុកនៅក្នុងសាសនាចក្រដែរ។ ពរជ័យបព្វជិតភាពខ្លះ--- ដូចជា ពររបស់លោកអយ្យកោ --- ពាក្យពេចន៍ដែលនិយាយគឺជាខ្លឹមសារដ៏សំខាន់សំរាប់ការប្រសិទ្ធពរ។ ប៉ុន្តែនៅក្នុងពរជ័យ នៃការព្យាបាល--- មានផ្នែកនៃពរជ័យជាច្រើនទៀត--- ការលាបប្រេង ការផ្សាភ្ជាប់ សេចក្តីជំនឿ និងតាមព្រះហឫទ័យរបស់ព្រះអម្ចាស់--- ដែលជាធាតុដ៏សំខាន់។

វាសំខាន់ណាស់ អែលឌើរធ្វើការនោះនឹងត្រូវទទួលការបំផុសពីព្រះវិញ្ញាណនៃព្រះអម្ចាស់ គាត់នឹងដឹងហើយត្រូវប្រកាស ពីព្រះហឫទ័យនៅក្នុងពាក្យអធិស្ឋាន។ ព្រិកហាំ យ៉ង់ បានបង្រៀនអ្នកដឹកនាំបព្វជិតភាពថា៖ «វាគឺជាឯកសិទ្ធ និងកតាព្វកិច្ចរបស់អ្នកក្នុងការរស់នៅ ដូច្នេះអ្នកនឹងដឹងពេលណាព្រះបន្ទូលរបស់ព្រះអម្ចាស់ត្រូវនិយាយ ទៅកាន់អ្នក ហើយនៅពេលណាគំនិតរបស់ព្រះអម្ចាស់ត្រូវបើកសម្តែងដល់អ្នក»។ 7 នៅពេលរឿងនោះកើតឡើង នោះពរជ័យដែលបានថ្លែងនឹងត្រូវបានបំពេញចំៗ និងអស្ចារ្យបំផុត។ នៅក្នុងឱកាសពិសេសខ្លះ ខ្ញុំបានទទួលបទពិសោធន៍ ដែលពិតជាមាន ការបំផុសគំនិតចំពោះពរជ័យនៃការប្រសិទ្ធពរ ហើយបានដឹងថា អ្វីដែលខ្ញុំនិយាយគឺជា ព្រះហឫទ័យរបស់ ព្រះអម្ចាស់។ ទោះជាយ៉ាងណាក្តី ដូចជាអ្នកធ្វើការនៅក្នុងការប្រសិទ្ធិពរដល់អ្នកឈឺទូទៅដែរ ជាញឹកញាប់ខ្ញុំមានភាពស្មុគ្រស្មាញជាមួយព្រះបន្ទូលមិនច្បាស់លាស់នូវអ្វីដែលខ្ញុំគួរនិយាយ។ អែលឌើរគ្រប់រូបមានបទពិសោធន៍កើនឡើង និងថយចុះ នៅក្នុងកំរិតរបស់គាត់ អំពីការដឹងចំពោះការបំផុសគំនិត ពីព្រះវិញ្ញាណតាមមធ្យោបាយផ្សេងៗ។ អែលឌើរគ្រប់រូបដែលផ្តល់ការប្រសិទ្ធពរមួយ គឺស្ថិតនៅក្រោមឥទ្ធិពល បំណងប្រាថ្នារបស់អ្នកដែលមានការឈឺចាប់។ ភាពមិនល្អឥតខ្ចោះនិមួយៗទាំងនេះ និងភាពមិនល្អឥតខ្ចោះខាងជីវិតរមែងស្លាប់ដទៃទៀត អាចមានឥទ្ធិពលចំពោះ ពាក្យពេចន៍ ដែលយើងនិយាយចេញមក។

ជាកុសលល្អ ពាក្យពេចន៍ដែលនិយាយក្នុងការប្រសិទ្ធពរព្យាបាល មិនសំខាន់ចំពោះឥទ្ធិពលនៃការជាសះស្បើយទេ។ ប្រសិបើមានសេចក្តីជំនឿគ្រប់គ្រាន់ ហើយបើវាជាព្រះហឫទ័យរបស់ព្រះអម្ចាស់ នោះអ្នកឈឺចាប់នោះ នឹងបានជា សះស្បើយ ឬបានទទួលពរ ទោះបីជាការធ្វើកិច្ចការនោះនិយាយពាក្យទាំងនោះឬ

អត់ក្តី។ ផ្ទុយទៅវិញ បើអ្នកធ្វើកិច្ចការមានទំនោរទៅតាមបំណងប្រាថ្នាផ្ទាល់ខ្លួន ឬគ្មានបទពិសោធន៍ ហើយផ្តល់ជាយោបល់ ឬពាក្យប្រសិទ្ធពរនោះ លើសពីអ្វីដែលព្រះអម្ចាស់ជ្រើសរើសប្រទានឱ្យស្របតាម សេចក្តីជំនឿ នៃបុគ្គលម្នាក់ៗនោះ នោះពាក្យពេចន៍ទាំងនោះ នឹងមិនបំពេញទេ។ ដូច្នេះហើយ គ្មានអែលឌើរណាម្នាក់គួរស្ទាក់ស្ទើរ ក្នុងការចូលរួមក្នុងពិធីប្រសិទ្ធពរព្យាបាលនោះទេ ពីព្រោះដោយការភ័យខ្លាចថាគាត់មិនដឹងថានឹងត្រូវនិយាយអ្វី។ ពាក្យដែលត្រូវនិយាយនៅក្នុង ពិធីប្រសិទ្ធពរព្យាបាល អាចធ្វើឱ្យសេចក្តីជំនឿអស់អ្នកដែលឮពាក្យទាំងនោះបាន ស្អាងឡើង និងមានឋាមពល ប៉ុន្តែឥទ្ធពលនៃពរជ័យ គឺអាស្រ័យលើសេចក្តីជំនឿ និងព្រះហឫទ័យរបស់ព្រះអម្ចាស់ គឺមិនអាស្រ័យទៅលើពាក្យពេចន៍ ដែលបាននិយាយដោយ អែលឌើរដែលធ្វើកិច្ចការនោះទេ។

## ព្រះហឫទ័យរបស់ព្រះអម្ចាស់

ទាំងយុវជន និងបុរសចំណាស់ទាំងឡាយ សូមធ្វើការកត់ចំណាំជាពិសេសចំពោះអ្វីដែលខ្ញុំនឹងនិយាយនៅពេលនេះ។ ខណៈពេលយើងអនុវត្តតាមព្រះចេស្តាដែលគ្មានការសង្ស័យនៃបព្វជិតភាពនៃព្រះ ហើយនៅពេលយើងឱ្យតម្លៃចំពោះសេចក្តីសន្យា ដែលទ្រង់នឹងឮ ហើយនឹងឆ្លើយតបចំពោះការអធិស្ឋានដោយសេចក្តីជំនឿ សូមយើងត្រូវចងចាំជានិច្ចថា សេចក្តីជំនឿ និងអំណាចនៃការព្យាបាល នៃបព្វជិតភាពមិនចេញជាលទ្ធផលផ្ទុយពីព្រះហឫទ័យរបស់ទ្រង់ អំពីបព្វជិតភាពនោះឡើយ។ គោលការណ៍នេះបានបង្រៀននៅក្នុងវិវរណៈ ដោយបានចង្អុលបង្ហាញថា អែលឌើរនៃសាសនាចក្រ គួរតែ ដាក់ដៃនៅលើ ក្បាលមនុស្សឈឺ។ ព្រះអម្ចាស់សន្យាថា « អ្នកណាដែលមានសេចក្តីជំនឿជឿដល់យើង ដើម្បីឱ្យបានជាសះស្បើយ *ហើយដែលពុំបានកំណត់ឱ្យស្លាប់* នោះនឹងត្រូវបានជាស្បើយហើយ» (គ. និង ស. 42:48 ជាការបញ្ជាក់ បន្ថែម)។ ស្រដៀងគ្នានេះដែរ នៅក្នុងវិវរណៈសម័យទំនើប ព្រះអម្ចាស់បានប្រកាសថានៅពេលមនុស្សម្នាក់ «សូមតាម ព្រះហឫទ័យរបស់ព្រះ… ត្រូវបានសំរេចតាមសំណូមពររបស់គេ» (គ. និង ស. 46:30 សូមមើលផងដែរ ហេលេមិន 10:5 យ៉ូហានទី1 5:14 )។

ចេញពីព្រះគម្ពីរទាំងអស់នេះយើងបានរៀនថា សូម្បីតែអ្នកបំរើរបស់ព្រះអម្ចាស់ ក៏ត្រូវអនុវត្តអំណាចដ៏ទេវភាពរបស់ទ្រង់នៅក្នុងស្ថានភាព ដែលត្រូវការសេចក្តីជំនឿគ្រប់គ្រាន់ ដើម្បីបានការជាសះស្បើយពរជ័យនៃបព្វជិតភាព មិនអាចប្រទានឱ្យមនុស្សម្នាក់នឹងបានជាសះស្បើយ ប្រសិនបើវាការព្យាបាលពុំមែនជាព្រះហឫទ័យរបស់ព្រះអម្ចាស់នោះ។

ក្នុងនាមជាកូនរបស់ព្រះ ការដឹងអំពីសេចក្តីស្រឡាញ់ដ៏អស្ចារ្យ និងចំណេះដឹងដ៏ខ្ពស់បំផុតរបស់ទ្រង់ នៃអ្វីដែលប្រសើរបំផុតសម្រាប់សុខមាលភាពដ៏អស់កល្បជានិច្ចរបស់យើង នោះយើងនឹងមានទំនុកចិត្តលើទ្រង់។ គោលការណ៍ទីមួយនៃដំណឹងល្អគឺសេចក្តីជំនឿលើព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ហើយសេចក្តីជំនឿមានន័យថាទុកចិត្ត។ ខ្ញុំមានអារម្មណ៍ ទុកចិត្តចំពោះអ្វីដែលជីដូនមួយរបស់ខ្ញុំបានថ្លែងនៅក្នុងពិធីបុណ្យសព របស់ក្មេងស្រីជំទង់ម្នាក់ ដែលបានស្លាប់ដោយសារ ជម្ងឺធ្ងន់ធ្ងរ។ គាត់និយាយពាក្យទាំងនេះដែលធ្វើ

ឱ្យខ្ញុំដំបូងមានចិត្តរំភើប ហើយបន្ទាប់មក បានស្អាងខ្ញុំឡើង៖ «ខ្ញុំដឹងថា វាជាព្រះទ័យរបស់ព្រះអម្ចាស់ដែលនាងស្លាប់។ នាងបានទទួលការព្យាបាលតាមវេជ្ជសាស្ត្រយ៉ាងល្អ។ នាងបានទទួលពរជ័យបព្វជិតភាព។ ឈ្មោះរបស់នាងបានសរសេរនៅលើក្រដាសអធិស្ឋាន ក្នុងព្រះវិហារបរិសុទ្ធ។ នាងគឺជាប្រធានបទមួយដែលមនុស្សរាប់រយនាក់បានអធិស្ឋានសុំឱ្យមានសុខភាពល្អឡើងវិញ។ ហើយដឹងថាក្នុងគ្រួសារនាងមានសេចក្ដីជំនឿគ្រប់គ្រាន់ថា នាងនឹងបានជាសះស្បើយឡើងវិញ លើកលែងតែនោះជា បំណងប្រាថ្នារបស់ព្រះអម្ចាស់ថា ត្រូវនាំ នាងត្រឡប់ទៅផ្ទះវិញក្នុងពេលនេះ»។ ខ្ញុំមានអារម្មណ៍ទុកចិត្តដូច្នេះដូចគ្នា ចំពោះពាក្យសំដីរបស់ឪពុកម្នាក់ទៀត អំពីកូនស្រីជំរើសម្នាក់ផ្សេងទៀតដែលបានស្លាប់ នៅពេលថ្មីៗនេះដោយជម្ងឺមហារីកក្នុងយុវវ័យរបស់នាង។ គាត់ប្រកាសថា៖ «សេចក្ដីជំនឿ របស់គ្រួសារយើង គឺនៅក្នុងព្រះយេស៊ូវគ្រីស្ទ គឺមិនពឹងផ្អែកទៅលើ លទ្ធផលអ្វីផ្សេងទេ»។ ការបង្រៀននេះគឺពិតណាស់ ចំពោះខ្ញុំ។ យើងធ្វើអ្វីគ្រប់យ៉ាងដែលយើងអាច ដើម្បីព្យាបាលមនុស្ស ជាទីស្រឡាញ់របស់យើង ហើយបន្ទាប់មក យើង ទុកចិត្តលើព្រះអម្ចាស់ចំពោះលទ្ធផលចុងក្រោយ។

ខ្ញុំសូមថ្លែងទីបន្ទាល់អំពីអំណាចបព្វជិតភាពរបស់ព្រះ អំពីអំណាចនៃការអធិស្ឋានដោយក្ដីជំនឿ និងអំពីសេចក្ដីពិតនៃគោលការណ៍ទាំងនេះ។ លើសពីនោះ ខ្ញុំថ្លែងទីបន្ទាល់ អំពីព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ដែលយើងបំរើ ដែលការរស់ឡើងវិញរបស់ទ្រង់ បានផ្ដល់ដល់យើងនូវការធានាអំពីអមតភាព ហើយដង្វាយធួនរបស់ទ្រង់ បានផ្ដល់ឱកាសដល់យើង សម្រាប់ជីវិតដ៏អស់កល្បជានិច្ច ជាអំណោយទានដ៏ល្អបំផុតលើសអស់ទាំងអំណោយទាននៃព្រះ។ នៅក្នុងព្រះនាមនៃព្រះយេស៊ូវ គ្រីស្ទ អាម៉ែន។

កំណត់ចំណាំ


1. Discourses of Brigham Young (Deseret Book Co., 1978) ទំព័រ 163។

2. «US Religious Landscape Survey: Religious Beliefs and Practices: Diverse and Politically Relevant» (The Pew Forum on Religion and Public Life ខែ មិថុនា ឆ្នាំ 2008), cited in Micklethwait & Wooldridge «God is Back» [New York, New York: The Penguin Press ឆ្នាំ 2009] ទំព័រ 131។

3. Dallas Morning News ថ្ងៃទី 30 ខែ មករា ឆ្នាំ 2000 ទំព័រ 31A។

4. Discourses of Brigham Young ទំព័រ 162 សូមមើលផងដែរ Russell M. Nelson «Neither Trust in the Arm of Flesh» Ensign ខែ មិនា ឆ្នាំ 2010 ទំព័រ 24 Gordon B. Hinckley, Teachings of Gordon B. Hinckley (Deseret Book Co. ឆ្នាំ 1997) ទំព័រ 474 ។

5. «President Kimball Speaks Out on Administration to the Sick» New Era ខែ តុលា ឆ្នាំ 1981 ទំព័រ 47 Tambuli  ខែ សីហា ឆ្នាំ  1982 ទំព័រ 37។

6. Ibid។

7. Discourses of Brigham Young ទំព័រ 163។